ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១១៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតបណ្តាញអគ្គលេខាធិការនៃក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/២៣១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៣១៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៣២៥ អនក្រ.បក ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ១៤១ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥ ស្ដីពីការបង្កើតគណៈកម្មាធិការលើកកម្ពស់អភិបាលកិច្ចក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ
- បានឃើញអនុក្រឹត្យលេខ១២៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើត **បណ្ដាញអគ្គលេខាធិការនៃក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ** ដែលហៅកាត់ថា "**បណ្ដាញអគ្គលេខាធិការ**" ដើម្បីសម្របសម្រួលការអនុវត្តមុខងារគាំទ្ររបស់ក្រសួង ស្ថាប័ន ក្នុងការលើកកម្ពស់និងពង្រឹងអភិបាលកិច្ចក្នុងរដ្ឋបាលសាធារណៈ និងជំរុញការចូលរួមអនុវត្តការងារកែទម្រង់របស់រាជរដ្ឋាភិបាល ប្រកបដោយសង្គតិភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន និងអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័នចំណុះអង្គការនីតិប្រតិបត្តិ លើកលែងក្រសួងការពារជាតិ។

## ជំពូកទី២

## ការសម្របសម្រួលរបស់បណ្ដាញអគ្គលេខាធិការ

**មាត្រា៣ .-**

បណ្ដាញអគ្គលេខាធិការ ជាយន្តការតភ្ជាប់ទំនាក់ទំនង កិច្ចសហការ និងសម្របសម្រួលការងាររវាងអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន និងអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន ដើម្បីកាត់បន្ថយបញ្ហាប្រឈមដែលមានភាពប្រទាក់ក្រឡា និងស្មុគស្មាញ សំដៅជួយគាំទ្រគ្នាទៅវិញទៅមកក្នុងការលើកកម្ពស់និងពង្រឹងប្រសិទ្ធភាពការងារ។

បណ្ដាញអគ្គលេខាធិការ ផ្ដោតជាសំខាន់លើការសម្របសម្រួលក្នុងការអនុវត្តមុខងារគាំទ្ររបស់ក្រសួង ស្ថាប័ន ដូចខាងក្រោម៖

- ការពង្រឹងអភិបាលកិច្ចក្នុងរដ្ឋបាលសាធារណៈ នៅតាមក្រសួង ស្ថាប័នចំណុះអង្គការនីតិប្រតិបត្តិ
- ការពង្រឹងកិច្ចសហការ និងចូលរួមអនុវត្តការងារដោយប្រទាក់ក្រឡារវាងអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន
- សម្របសម្រួលនិងគាំទ្រគ្នាទៅវិញទៅមកដើម្បីកាត់បន្ថយបញ្ហាប្រឈមដែលមានភាពប្រទាក់ក្រឡា និងស្មុគស្មាញនៃដំណើរការរដ្ឋបាល ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពការងារ
- សហការនិងពង្រឹងការអនុវត្តមុខងារគាំទ្រនៅតាមក្រសួង ស្ថាប័នឱ្យមានសង្គតិភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព
- ជំរុញការប្រាស្រ័យទាក់ទងគ្នា ការចែករំលែកទិន្នន័យនិងព័ត៌មានរវាងក្រសួង ស្ថាប័ន

- សិក្សានិងកំណត់បញ្ហាប្រឈមនិងលើកសំណើដំណោះស្រាយទាំងឡាយដែលពាក់ព័ន្ធនឹងការអនុវត្តមុខងារគាំទ្រ
- ចែករំលែកបទពិសោធ ចំណេះដឹងអំពីភាពជាអ្នកដឹកនាំ ឧត្តមានុវត្តន៍ និងនវានុវត្តន៍ពាក់ព័ន្ធនឹងការដឹកនាំអង្គភាព វិធីសាស្ត្រដោះស្រាយបញ្ហា ការរៀបចំយុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការថវិកា និងគម្រោងនានា
- ការពង្រឹងនិងអភិវឌ្ឍសមត្ថភាពក្នុងក្របខ័ណ្ឌបណ្ដាញអគ្គលេខាធិការ។

## ជំពូកទី៣
## ស្ថាប័នដឹកនាំនិងសម្របសម្រួល

**មាត្រា៤ ._**

បណ្ដាញអគ្គលេខាធិការ ត្រូវដឹកនាំនិងសម្របសម្រួលដោយរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

**មាត្រា៥ ._**

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បំពេញមុខងារគាំទ្រដល់កិច្ចដំណើរការនៃបណ្ដាញអគ្គលេខាធិការ។

## ជំពូកទី៤
## ការប្រព្រឹត្តទៅនៃបណ្ដាញអគ្គលេខាធិការ

**មាត្រា៦ ._**

បណ្ដាញអគ្គលេខាធិការ មានរបបប្រជុំជាទៀងទាត់រៀងរាល់ត្រីមាស ឬកិច្ចប្រជុំតាមការចាំបាច់ ដែលត្រូវដឹកនាំសម្របសម្រួលដោយរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ឬរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈតាមការប្រគល់សិទ្ធិពីរដ្ឋមន្ត្រី។

រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈអាចអញ្ជើញប្រធានអង្គភាពពាក់ព័ន្ធផ្សេងទៀតរបស់ក្រសួង ស្ថាប័ន ចូលរួមប្រជុំតាមការចាំបាច់។

កិច្ចប្រជុំរបស់បណ្ដាញអគ្គលេខាធិការ ត្រូវមានសមាសភាពចូលរួមពី អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន និងអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន។ ដើម្បីជានានិរន្តរភាព និងប្រសិទ្ធភាពការងារនៃបណ្ដាញអគ្គលេខាធិការ រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ត្រូវចាត់តាំងឱ្យមានអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន ឬអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ១(មួយ)រូប តាមសំណើរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ឬអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន ជាអគ្គលេខាធិការជំនួស ដើម្បីបំពេញការងារក្នុងបណ្ដាញអគ្គលេខាធិការ ក្នុងករណីអវត្តមានអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ឬអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន។

**មាត្រា៧ ._**

អគ្គលេខាធិការ និងអគ្គនាយក ដែលចូលរួមក្នុងបណ្ដាញអគ្គលេខាធិការ ទទួលបានការលើកទឹកចិត្តផ្អែកលើសមិទ្ធកម្មដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា៨ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



ទ

**មាត្រា៩ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១០ រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ហ៊ុន ម៉ានី**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ